ខ្លួនឯង ។ យើងទាំងអស់គ្នាក៏មានកាតព្វកិច្ចដើម្បីផ្លាស់ប្តូរនូវគំនិតចាស់ចេញ ហើយត្រូវចាំ កូនក្មេងនិងមនុស្សពេញវ័យដែលមានជម្ងឺដោនសីនដ្រូម មិនមែនត្រូវជាប់នៅក្នុងមណ្ឌលអប់រំទេ គឺអាចរស់នៅក្នុងសង្គម មានការទទួលស្គាល់ គោរព និងមានសិទ្ធិ-លទ្ធភាពដូចតែអ្នកឯទៀតដែរ ។

ចំពោះពត៌មានបន្ថែមទៀត ចូរទាក់ទងមក **The Down Syndrome Association of NSW , PO Box 2356 , North Parramatta , 2151** ទូរស័ព្ទ ( 02 ) 683 4020 ឬសមាគមន៍ **The Early Intervention Association** ទូរស័ព្ទ ( 02 ) 412 1709 ឬ " ផ្នែកខាងការលូតលាស់ក្មេងអាណិកជន" **Ethnic Child Care Development Unit** ទូរស័ព្ទ ( 02 ) 569 1288 ឬ ផ្នែកជួយភាពពិការពហុវប្បធម៌ **Multi-Cultural Disability Service** ( 02 ) 891 6400 ៕

**********************

លេខទូរស័ព្ទទាំងនេះត្រឹមត្រូវនៅពេលបោះពុម្ភក៏ប៉ុន្តែអាចមិនបានកែតម្រូវតាមការលៈទេសៈ។ លោក-អ្នក ប្រហែ អាចត្រូវមើលបញ្ជាក់លេខនៅក្នុង“សៀវភៅទូរស័ព្ទ” (Telephone Directory)។

NSW Multicultural Health Communication Service
Website: http://www.mhcs.health.nsw.gov.au
Email: mhcs@sesiahs.health.nsw.gov.au
Tel: (02) 9816 0347

multicultural health communication

Khmer
[BHC-3370]

# ការចិញ្ចឹមកូនដែលមានជម្ងឺខួរក្បាល ម្យ៉ាងហៅ “ ដោនសីនដ្រូម ”

## Bringing Up Children with Down Syndrome

NSW GOVERNMENT | Health

# ការចិញ្ចឹមកូនដែលមានជម្ងឺខួរក្បាល ម្យ៉ាងហៅ " ដោនសីនដ្រូម "

## Bringing Up Children with Down Syndrome

នៅក្នុងវ័យប្រាំបួនឆ្នាំ Mary ជាក្មេងស្រីមួយរូសរាយ មានចិត្តសប្បាយរីករាយ ពេញចិត្តក្នុងការរៀនសូត្រ ចូលចិត្តលេងកីឡា gymnastics និងហែលទឹក ហើយដែលបងប្អូនមាតាបិតាស្រឡាញ់ពេញចិត្តនិងនាងយ៉ាងខ្លាំង ។

ក៏ប៉ុន្តែក្នុងពិភពលោកនេះនៅក្នុងប្រទេសខ្លះ ជីវភាពរបស់ក្មេងខ្លះដែលមានអាយុប្រហែល Mary នោះមានសភាពខុសស្រឡះពីនេះ ។ ពីព្រោះក្មេងខ្លះកើតជម្ងឺខួរក្បាលម្យ៉ាងហៅ " ដោនសីនដ្រូម " Down syndrome គឺជាជម្ងឺពីកំណើតម្យ៉ាងដែលបណ្តាលឲ្យពិការ ( ខូច ) ប្រាជ្ញា ។ ជារឿយៗ គេតែងគិតថាមិនអាចអប់រំអ្នកជម្ងឺនោះបានឡើយ ។ អ្នកជម្ងឺអាចមានជីវិតរស់នៅយ៉ាងគ្រៀមក្រោះ ហើយអាចត្រូវរស់នៅក្នុងមណ្ឌលអប់រំដាច់ចេញពីគ្រួសារ ។

ក៏ប៉ុន្តែដោយសារគេមានកម្មវិធីអប់រំពិសេសមួយដែលគេហៅថា " ការឆាប់ធ្វើអន្តរាគមន៍ " ( Early Intervention ) កូនក្មេងនៅក្នុងប្រទេសអូស្ត្រាលីដែលកើតមកមានជម្ងឺដោនសីនដ្រូម អាចមានជីវភាពរស់នៅពេញលេញដោយរីករាយ ។ កូនក្មេងទាំងនោះភាគច្រើនអាចទៅសាលារៀន និងចូលរួមក្នុងសកម្មភាពផ្សេងៗដូចដែលក្មេងធម្មតាចូលចិត្តលេងមានដូចជា កីឡា ការរាំលេង និងការលេងល្ខោន - និងដោយសារមនុស្សក្នុងសង្គមកាន់តែមានទឹកចិត្តសន្តោសយោគយល់ ឥឡូវនេះមានក្រុមហ៊ុនជាច្រើនដែលផ្តល់ការងារដល់ក្មេងដែលមានជម្ងឺដោនសីនដ្រូម ។

នាបច្ចុប្បន្នកាលនេះវេជ្ជបណ្ឌិតឲ្យឱវាទថា គួរតែឆាប់ឲ្យមានការធ្វើអន្តរាគមន៍ ផ្តល់កម្មវិធីដល់កូនក្មេងដែលកើតមកមានអសមត្ថភាពឬពិការ ។ ដោយសារការឧបត្ថម្ភពីមាតាបិតា ហើយនិងគ្រូអប់រំពិសេស នៅពេលអាយុបាន ៣ អាទិត្យ Mary បានចាប់ផ្តើមការព្យាបាលដោយវិធីហាត់ប្រាណ ( physiotherapy ) និងការឆាប់អប់រំ ដែលជាយវាហេតុនាំឲ្យ Mary ចេះដឹងសំរាប់ចូលរៀនមតេយ្យសាលា និសាលារៀនតទៅទៀត ។ ឥឡូវនេះ Mary ទៅសាលារៀនដូចតែបងវា ហើយ Mary បានទទួលការអប់រំបន្ថែមទៀតពីគ្រូដែលមានការហ្វឹកហ្វឺនជាពិសេស ។

ម្តាយ Mary ពោលថា " យើងស្រឡាញ់កូនយើងទាំងពីរនាក់ណាស់ - យើងមិនអាចសន្និឋានត្លូវជីវិតយើងដោយគ្មានវាទាំងពីរនោះទេ ។ ការដឹងនិងយល់ពីក្មេងដែលមានជម្ងឺដោនសីនដ្រូមក៏កាន់តែចំរើនឡើងជានិច្ច ។ ប្រជាជនជាទូទៅចាប់យល់ថា អ្នកដែលមានជម្ងឺដោនសីនដ្រូមក៏ជាមនុស្សមានតម្លៃម្នាក់ក្នុងសង្គមដូចអ្នកឯទៀតដែរ ។ "

ជម្ងឺដោនសីនដ្រូម ជាបញ្ហាមួយដែលកើតមានឡើងដល់គ្រប់ជាតិសាសន៍ ហើយគ្រោះថ្នាក់ចំពោះទារកដែលកើតមកមានជម្ងឺនេះក៏កាន់តែកើនឡើងដែរបើកាលណាម្តាយមានវ័យកាន់តែចាស់ ។ ឧទាហរណ៍ ក្នុងចំណោមស្ត្រីមួយរយនាក់ដែលមានវ័យពី ៤០ ឆ្នាំទៅ និងមានស្ត្រីម្នាក់ដែលមានទារកកើតមកមានជម្ងឺដោនសីនដ្រូម ។ ក្រៅពីពិការខាងប្រាជ្ញា ជម្ងឺនេះអាចបណ្តាលឲ្យមានការពិបាកខាងសុខភាពផ្សេងទៀតដូចជា ខាងចក្ខុវិស័យ ខាងការនិយាយ និងសោតវិញ្ញាណ ។

ប្រតិកម្មរបស់មាតា-បិតានៅពេលគេប្រាប់ថា កូនកើតមកមានជម្ងឺដោនសីនដ្រូមអាចមានដូចជា ការតក់ស្លុត សេចក្តីទុក្ខព្រួយ ការឈឺចាប់ សេចក្តីខឹង និងការខកចិត្ត ។ ដូចមានមាតា-បិតាមួយពោលថា " ខ្ញុំចេះតែខំសំឡឹងមើលកូនង៉ាខ្ញុំហើយគិតថា ' ហេតុដូចម្តេចបានជាហេតុនេះកើតឡើងដល់គ្រួសារខ្ញុំ ? ឬដល់កូនខ្ញុំ ? ខ្ញុំមិននឹកគិតថា ខ្ញុំអាចដោះស្រាយរឿងនេះបានឡើយ ' ។ "

ក៏ប៉ុន្តែយោងទៅតាមសមាគមន៍ ដោនសីនដ្រូម ( Down Syndrome Association ) មាតាបិតាភាគច្រើនអាចលៃលករឿងនេះបាន ។ សមាគមន៍នេះជាអង្គការផ្តល់ការឧបត្ថម្ភ និងពត៌មានដល់មាតាបិតាដែលមានកូនពិការ ។ បើចាំបាច់គេអាចរកអ្នកបកប្រែជូន ។ ជារឿយៗវាអាចជួយសំរាលអ្នក បើកាលណាអ្នកបាននិយាយជាមួយមាតាបិតាឯទៀតដែលមានបញ្ហាដូចគ្នានេះ ។ បើអាចធ្វើទៅកើត សមាគមន៍ ដោនសីនដ្រូមនិងជួយឲ្យអ្នកអាចទាក់ទងទៅមាតាបិតាដែលចេះនិយាយដូចគ្នាហើយដែលមានកូនកើតជម្ងឺដោនសីនដ្រូម ។

ក៏ប៉ុន្តែ វាមិនមែនស្រេចតែមាតាបិតាប៉ុណ្ណោះទេសំរាប់ជួយកូនក្មេងទាំងនេះឲ្យបានចំរើនលូតលាស់ទៅជាមនុស្សពេញវ័យសប្បាយចិត្ត ហើយទុកចិត្ត